**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ...១៣៣...បទ.ប្រក............

# ប្រកាស
# ស្តីពី
# ការតភ្ជាប់ និងការផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ពីប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ១២៦ បទ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ០៩០ បទ.ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**ប្រការ១.**

ប្រកាសនេះមានគោលបំណងធានានូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ក្នុងការតភ្ជាប់ និងការផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ពីប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC)។

**ប្រការ២.**

ប្រកាសនេះមានគោលដៅកំណត់នីតិវិធី និងលក្ខខណ្ឌសម្រាប់៖

- ការផ្តល់ព័ត៌មានបច្ចេកទេស និងព័ត៌មានសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា
- ការតភ្ជាប់បណ្តាញផ្ទាល់ (Direct Link) ពីគ្រប់ប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC)
- ការបញ្ជូនទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ដោយស្វ័យប្រវត្ត (Auto Transfer) ជាអចិន្ត្រៃយ៍។

**ប្រការ៣.**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤.**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ ត្រូវផ្តល់ព័ត៌មានបច្ចេកទេស និងព័ត៌មានសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា នៅក្នុងប្រព័ន្ធរបស់ខ្លួន ដោយអនុវត្តដូចខាងក្រោម ៖

- ត្រូវបំពេញចម្លើយឱ្យបានត្រឹមត្រូវទៅតាមកម្រងសំណួរបច្ចេកទេសគោល (Main Technical Questionnaire) ដែលមាននៅក្នុង**ឧបសម្ព័ន្ធទី១** និងកម្រងសំណួរបច្ចេកទេសបន្ថែម (Technical Questionnaire Addendum) ដែលមាននៅក្នុង**ឧបសម្ព័ន្ធទី២** ចំពោះប្រតិបត្តិករទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ
- ត្រូវបំពេញកម្រងសំណួរបច្ចេកទេស ដែលមាននៅក្នុង**ឧបសម្ព័ន្ធទី៣** ចំពោះប្រតិបត្តិករទូរគមនាគមន៍ផ្តល់សេវា (ISP/VoIP)
- ត្រូវផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ឱ្យបានមុន ០៣(បី)ខែ នូវរាល់ការផ្លាស់ប្តូរ ឬកែប្រែប្រព័ន្ធបច្ចេកទេស និងទិន្នន័យផ្សេងៗទៀត ជាអាទិ៍ ឈ្មោះក្រុមហ៊ុន ទីតាំងក្រុមហ៊ុន ក្បាលលេខទូរស័ព្ទ (Prefixed Number) លេខកូដ និងទម្រង់វិក្កយបត្រ
- ត្រូវចាត់តាំងអ្នកបច្ចេកទេសទៅតាមជំនាញនីមួយៗ ដើម្បីពន្យល់បញ្ជាក់បន្ថែមលើព័ត៌មានដែលបានបំពេញក្នុងកម្រងសំណួរបច្ចេកទេស ឬ/និងឆ្លើយបំភ្លឺទៅនឹងសំណួរពាក់ព័ន្ធ (Clarification

Questionnaire) ដទៃទៀតក្នុងករណីចាំបាច់ ដោយសហការឱ្យបានពេញលេញ និងទាន់ពេលវេលាជាមួយមន្ត្រីនៃមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា

- ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់មន្ត្រីនៃមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ឬ/និងថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ៥.**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ ត្រូវតភ្ជាប់បណ្តាញដោយផ្ទាល់ ជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ដោយអនុវត្តដូចខាងក្រោម ៖

- ត្រូវធ្វើការតភ្ជាប់បណ្តាញដោយផ្ទាល់ជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ស្របទៅតាមគោលការណ៍ណែនាំ ដូចមាននៅក្នុង **ឧបសម្ព័ន្ធទី៤** ចំពោះប្រតិបត្តិករទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ ឬ/និង **ឧបសម្ព័ន្ធទី៥** ចំពោះប្រតិបត្តិករទូរគមនាគមន៍ផ្តល់សេវា (ISP/VoIP)
- ត្រូវបង្កលក្ខណៈងាយស្រួលដល់ក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ចុះទៅសិក្សាទីតាំង (Site Survey) ដូចមាននៅក្នុង **ឧបសម្ព័ន្ធទី៦** ដើម្បីពិនិត្យលទ្ធភាពដំឡើងឧបករណ៍បរិក្ខាបច្ចេកទេសរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) នៅទីតាំងរបស់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ត្រូវសហការផ្តល់ទីតាំង ចរន្តអគ្គិសនី និងសម្ភារៈបន្ទាប់បន្សំផ្សេងទៀត ដើម្បីបំពាក់ និងដំណើរការឧបករណ៍បញ្ជូនស៊ីញ៉ាល់ (Transmission Equipment) ម៉ាស៊ីនមេផ្ទុក-បញ្ជូនទិន្នន័យ (FTP Server) និងកំផែងសន្តិសុខទិន្នន័យ (Firewall) ក្នុងការបញ្ជូនទិន្នន័យឱ្យបានពេញលេញ និងទៀងទាត់
- ត្រូវផ្តល់កិច្ចសហការ និងអនុញ្ញាតឱ្យក្រុមការងារបច្ចេកទេស របស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ចូលទៅដំឡើង ត្រួតពិនិត្យ ថែទាំ និងជួសជុលឧបករណ៍បច្ចេកទេសទៅតាមការចាំបាច់ ។

**ប្រការ៦.**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ ត្រូវបញ្ជូនទិន្នន័យមកកាន់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ដោយអនុវត្តដូចខាងក្រោម ៖

- ត្រូវបំពាក់ឧបករណ៍បច្ចេកទេសសម្រាប់ កត់ត្រាទិន្នន័យត្រាហ្វិក (Traffic Data) ប្រព័ន្ធវិក្កយបត្រ (Billing System) និងបញ្ជូនទិន្នន័យដោយស្វ័យប្រវត្តិ (Auto Transfer)
- ត្រូវបញ្ជូនទិន្នន័យដោយស្វ័យប្រវត្តិ (Auto Transfer) មកកាន់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ឱ្យបានត្រឹមត្រូវ ពេញលេញ និងជាអចិន្ត្រៃយ៍តាមពេលវេលាជាក់ស្តែង (Real-Time) ជារៀងរាល់ពេលដែល CDR (Call Detail Record) ឬទិន្នន័យត្រូវបានបង្កើតចេញពីគ្រប់ប្រភពទិន្នន័យទាំងអស់ ដូចបានកំណត់នៅក្នុងកម្រងសំណួរបច្ចេកទេស

- ត្រូវបញ្ជូនទិន្នន័យឡើងវិញឱ្យបានត្រឹមត្រូវ និងពេញលេញ យ៉ាងយូរមួយសប្តាហ៍ក្រោយពីការជូនដំណឹងរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ក្នុងករណីខកខានក្នុងការបញ្ជូនទិន្នន័យ ឬ/នឹងបានបញ្ជូនទិន្នន័យខុសប្រក្រតី ដោយប្រការណាមួយ
- មិនត្រូវពន្យារពេល ឬ បដិសេធនៃការបញ្ជូនទិន្នន័យ ឬ/នឹងឃាត់ទុកផ្នែកណាមួយនៃទិន្នន័យ ពីគ្រប់ប្រភពទិន្នន័យទាំងអស់ ដូចដែលបានកំណត់នៅក្នុងកម្រងសំណួរបច្ចេកទេស។

**ប្រការ៧.**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងឡាយណា ដែលមិនអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិផ្សេងៗទៀត ជាធរមាន។

**ប្រការ៨.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគារធិការ ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធានអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៩
- ឯកសារ កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

| ល.រ | ចំណងជើង |
|---|---|
| ឧបសម្ព័ន្ធទី១ | កម្រងសំណួរបច្ចេកទេសគោលសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ (ទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ) |
| ឧបសម្ព័ន្ធទី២ | កម្រងសំណួរបច្ចេកទេសបន្ថែមសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ (ទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ) |
| ឧបសម្ព័ន្ធទី៣ | កម្រងសំណួរបច្ចេកទេសសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ផ្តល់សេវា ISP/VoIP |
| ឧបសម្ព័ន្ធទី៤ | ការតភ្ជាប់បណ្តាញដោយផ្ទាល់ រវាងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ និងប្រតិបត្តិករទូរគមនាគមន៍(ទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ) |
| ឧបសម្ព័ន្ធទី៥ | ការតភ្ជាប់បណ្តាញឯកជននិម្មិត (VPN) រវាងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) និង ប្រតិបត្តិករទូរគមនាគមន៍ផ្តល់សេវា ISP/VoIP |
| ឧបសម្ព័ន្ធទី៦ | ការសិក្សាទីតាំងរបស់ប្រតិបត្តិករទូរគមនាគមន៍ |